ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីសួងការគណនីនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

**សម្រេច**

**មាត្រាមួយ .-**

មាត្រា៦ មាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្ដីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា៦ ថ្មី .-**

ទូរគមនាគមន៍កម្ពុជាត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងពេញលេញ ដើម្បីបំពេញការងារក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្ដីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ និងលក្ខន្តិកៈរបស់ខ្លួន។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១រូប | ជាប្រធាន |
| - តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ១រូប | ជាសមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | ជាសមាជិក |
| - អគ្គនាយក **ទ.ក.** | ១រូប | ជាសមាជិក និង |
| - តំណាងនិយោជិតរបស់ **ទ.ក.** | ១រូប | ជាសមាជិក។ |

ក្នុងករណីតំណែងអគ្គនាយកនៅទំនេរ អគ្គនាយកស្ដីទី **ទ.ក.** មានសិទ្ធិនិងបុព្វសិទ្ធិដូចអគ្គនាយក **ទ.ក.** ដែរ។

**មាត្រា៩ ថ្មី .-**

ក្រុមប្រឹក្សាភិបាលមានរបបប្រជុំសាមញ្ញប្រចាំត្រីមាសនិងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញតាមគំនិតផ្ដួចផ្ដើមរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២/៣ (ពីរភាគបី) ឬពីអគ្គនាយក **ទ.ក.** តាមការចាំបាច់។ ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលមានធុរៈ សមាជិកណាម្នាក់ដែលមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលដែលមានវត្តមាន ត្រូវបានជ្រើសរើសជាប្រធានអង្គប្រជុំ។

ក្រុមប្រឹក្សាភិបាលត្រូវដំណើរការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈ ត្រូវជូនដំណឹងយ៉ាងតិច១០ថ្ងៃ ដោយភ្ជាប់នូវឯកសារពាក់ព័ន្ធ មុនពេលបើកកិច្ចប្រជុំ ដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកអង្គប្រជុំពាក់ព័ន្ធដទៃផ្សេងទៀត។

ក្រុមប្រឹក្សាភិបាលអាចដំណើរការប្រជុំបាន លុះត្រាតែមានសមាជិកលើសពី៥០% (ហាសិបភាគរយ) ចូលរួម។ សមាជិករបស់ក្រុមប្រឹក្សាភិបាលដែលអវត្តមាន ពុំអាចចាត់តំណាងជំនួសបានឡើយ។

ក្នុងករណីដែលសមាជិកចូលរួមប្រជុំលើកទី១ តិចជាងឬស្មើ ៥០% (ហាសិបភាគរយ) នោះប្រធានក្រុមប្រឹក្សាភិបាល អាចកោះអញ្ជើញប្រជុំលើកទី២ ក្នុងរយៈពេល១៥ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំលើកទី១។ ការប្រជុំលើកទី២ នេះ មិនចាំបាច់តម្រូវឲ្យមានសមាជិកគ្រប់ចំនួនកូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី១ ប៉ុណ្ណោះ។

អគ្គនាយក **ទ.ក.** ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ។ លេខាធិការពុំមានសិទ្ធិបោះឆ្នោតឡើយ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ដូចមានចែងក្នុងមាត្រា២៣ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃ១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែពុំមានសិទ្ធិបោះឆ្នោតឡើយ។

**មាត្រា១០ ថ្មី .-**

សមាជិកអង្គប្រជុំទាំងអស់ដែលចូលរួមប្រជុំក្រុមប្រឹក្សាភិបាល ត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងរក្សាទុកនៅទីស្នាក់ការនៃទូរគមនាគមន៍កម្ពុជា ដោយមានចុះហត្ថលេខារបស់ប្រធាន។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវរៀបចំនិងផ្ញើសេចក្តីព្រាងកំណត់ហេតុ ជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល ២ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិកក្រុមប្រឹក្សាភិបាល មានរយៈពេល ៥ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ ដែលទទួលបានការកែតម្រូវ ឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើ ត្រូវបញ្ជូនក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ ជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងជូនសមាជិកអង្គប្រជុំ។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាក់ សុខុន**

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ